**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០៥ សរណន**

# សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩

ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ។ នៅក្នុងប្រទេសកម្ពុជា ទិវាពលកម្មអន្តរជាតិថ្ងៃទី ០១ ខែ ឧសភា ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ ហើយបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានកំណត់យកថ្ងៃទី ០១ ខែ ឧសភា ជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការ និងកម្មករនិយោជិតទាំងអស់ ដូចថ្ងៃបុណ្យជាតិ បុណ្យប្រពៃណី និងបុណ្យអន្តរជាតិនានាដែរ។ ឆ្នាំ ២០០៩ នេះ ជាខួបលើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិ ដែលត្រូវប្រារព្ធស្របគ្នាជាមួយខួបលើកទី ៩០ នៃការបង្កើតអង្គការអន្តរជាតិខាងការងារ (ILO) ផងដែរ។

ស្ថិតក្នុងស្ថានភាពដែលវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកកើតឡើងជាទូទៅ ហើយមានផលប៉ះពាល់ដល់ប្រទេសយើងផងដែរនោះ ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ នេះ ជាព្រឹត្តិការណ៍មួយ ដែលយើងត្រូវនាំគ្នាឧទ្ទិសចំពោះគោលបំណងរួមរបស់យើង គឺ ***" ខិតខំបង្កើនផលិតភាពការងារ គុណភាពផលិតផល ដើម្បីជំនះការលំបាកនានារបស់ប្រទេសជាតិ "*** ។

អាស្រ័យហេតុនេះ ដើម្បីរៀបចំប្រារព្ធខួបអនុស្សាវរីយ៍លើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ នេះ ឱ្យប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដូចខាងក្រោមនេះ ៖

១-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើជាស្ថាប័នស្នូលក្នុងការរៀបចំទិវាអន្តរជាតិនេះ ដោយចេញសេចក្តីជូនដំណឹងដល់មន្ទីររាជធានី ខេត្តក្រោមឱវាទ អង្គការវិជ្ជាជីវៈរបស់និយោជក អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ម្ចាស់ និងនាយកក្រុមហ៊ុន ព្រមទាំងកម្មករ និយោជិត ដើម្បីណែនាំអំពីការឈប់សម្រាក និងបំផុសការជួបជុំសំណេះសំណាលស្វែងយល់ពីស្ថានភាពវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក ឬ កំសាន្តសប្បាយតាមលទ្ធភាពរៀងៗខ្លួនរបស់សហគ្រាស គ្រឹះស្ថាន សំដៅបង្កបរិយាកាសយោគយល់គ្នារវាងកម្មករ និយោជិត និងនិយោជក។

ខិតខំបញ្ចៀសការប្រើប្រាស់រូបភាពទិវាពលកម្មអន្តរជាតិ ដើម្បីធ្វើសកម្មភាពទាំងឡាយណាដែលបណ្តាលឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបស់សង្គម។

ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវជ្រើសរើសសហគ្រាស គ្រឹះស្ថាន ជានិមិត្តរូប ដើម្បីធ្វើការសំណេះសំណាលជាមួយកម្មករនិយោជិត ។

២-ក្រសួងព័ត៌មាន ត្រូវណែនាំប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជន ទទួលផ្សព្វផ្សាយសារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ ឱ្យបានទូលំទូលាយ ។

៣-ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធររាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវមានវិធានការតាមសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ក្នុងឱកាសទិវាពលកម្មអន្តរជាតិឆ្នាំ ២០០៩ នេះ ។

៤-ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋ ត្រូវណែនាំឱ្យមានការចងបដាពាក្យស្លោកនៅតាមក្រសួង ស្ថាប័ន អង្គភាពរដ្ឋគ្រប់លំដាប់ថ្នាក់ និងសហគ្រាស គ្រឹះស្ថានឯកជន យ៉ាងតិចចំនួនបី មានជាអាទិ៍ គឺ:

- **ជយោ! ព្រះរាជាណាចក្រកម្ពុជា**
- **អបអរសាទរខួបអនុស្សាវរីយ៍លើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិថ្ងៃទី០១ឧសភា**
- **ខិតខំបង្កើនផលិតភាពការងារ គុណភាពផលិតផល ដើម្បីជំនះការលំបាកនានារបស់ប្រទេសជាតិ ។**

រាជធានី និងខេត្តទាំងអស់ ត្រូវជ្រើសរើសផ្លូវវិថីសំខាន់ៗ និងទីតាំងរោងចក្រ សហគ្រាស ការដ្ឋាន កសិដ្ឋាន ដើម្បីធ្វើការចងបដាពាក្យស្លោក ។

៥-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមដោះស្រាយថវិកាឱ្យបានទាន់ពេលវេលា និងតាមគោលការណ៍កំណត់ ដើម្បីធានាការចាត់ចែងដំណើរការរៀបចំឱ្យបានសមស្របតាមគោលបំណង និងសំណូមពរ ។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ កម្មករនិយោជិតកម្ពុជា និងពលករបរទេសទាំងអស់ ចូលរួមអបអរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ ក្នុងក្តីសោមនស្សរីករាយ សាមគ្គីភាព និងភាតរភាព ដើម្បីឱ្យស័ក្តិសមជាបុណ្យការងាររបស់ប្រទេសជាតិយើង ដែលជាសមាជិកសហគមន៍អន្តរជាតិនានា នៅក្នុងពិភពលោក ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធររាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*

- *-ក្រសួងព្រះបរមរាជវាំង*
- *-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *-អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *-គ្រប់ក្រសួង ស្ថាប័ន*
- *-អភិបាលរាជធានី ខេត្ត*
- *-រាជកិច្ច*
- *-ឯកសារ-កាលប្បវត្តិ*